**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ០០៧៤/២០ ក.អ.ជ

ថ្ងៃអង្គារ ១២ រោច ខែ បុស្ស ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២០

# របាយការណ៍
# វឌ្ឍនភាពការងារប្រចាំខែធ្នូ ឆ្នាំ ២០១៩ និងទិសដៅការងារខែមករា ឆ្នាំ ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## ១.សេចក្ដីផ្ដើម

ខែធ្នូ ឆ្នាំ២០១៩ ជាខែចុងក្រោយនៃការអនុវត្តផែនការឆ្នាំ២០១៩ ដែលក្រសួងអភិវឌ្ឍន៍ជនបទបានខិតខំជម្នះដោះស្រាយបញ្ហានានាដែលកើតមានឡើងនៅតាមជនបទ ដើម្បីបំពេញសេចក្ដីត្រូវការប្រចាំថ្ងៃរបស់ប្រជាជន សំដៅលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាជន ឲ្យបានប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។ សេវាសាធារណៈជនបទដូចជាផ្លូវថ្នល់ជនបទ ទឹកស្អាត និងអនាម័យជនបទ ដែលជាហេដ្ឋារចនាសម្ព័ន្ធរូបវន្តត្រូវបានក្រសួងសាងសង់ ជួសជុល ថែទាំរួចជាស្រេច និងបានប្រគល់ជូនប្រជាជនប្រើប្រាស់ក្នុងសហគមន៍តាមផែនការដែលបានកំណត់ ។ ចំពោះបញ្ហាដែលនៅសេសសល់មួយចំនួនតូចនឹងត្រូវបន្តដោះស្រាយនៅឆ្នាំ២០២០ បន្តទៀតដែលក្រសួងបានបញ្ចូលក្នុងផែនការប្រចាំឆ្នាំរួចជាស្រេច ។ ការងារបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈមូលដ្ឋាន សហគមន៍ ជនជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ត្រូវបានអនុវត្តសម្រេចតាមផែនការដែលបានគ្រោងទុក ។

លទ្ធផលដែលក្រសួងសម្រេចបាន កំពុងឈានទៅផ្លាស់ប្ដូរលក្ខខណ្ឌរស់នៅរបស់ប្រជាជនកាន់តែល្អប្រសើរឡើង ។ លទ្ធផលសម្រេចបានក្នុងខែធ្នូ នេះមានដូចខាងក្រោម៖

## ២.វឌ្ឍនភាព

### ២.១. លទ្ធផលរួមរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

កម្មវិធីទាំង ៣ របស់ក្រសួងដែលបានអនុវត្តក្នុងខែធ្នូ ឆ្នាំ២០១៩ អនុវត្តបានជាង ៩៨% នៃផែនការក្នុងនោះកម្មវិធីកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទសម្រេចបាន ៩៥% ។ កម្មវិធីកិច្ចអន្តរាគមន៍គាំទ្រសេវាទំនាក់ទំនងជនបទសម្រេចបាន១០០% និងកម្មវិធីអភិវឌ្ឍធនធានមនុស្ស និងពង្រឹងស្ថាប័នសម្រេចបាន ១០០% នៃផែនការ ។

### ២.២.លទ្ធផលរបស់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ

#### ២.២.១.ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៩ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៧៩៧ នាក់



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែវិច្ឆិកា ឆ្នាំ២០១៩ គឺមានការថយចុះចំនួន ០១ នាក់ ដោយការផ្ទេរក្របខណ្ឌចេញ។ ក្រសួងបានទទួលលិខិតចូលចំនួន ១២៩ ច្បាប់ លិខិតចេញក្រៅក្រសួង ចំនួន ១៩១ ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ១១ ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ២១៣ ច្បាប់ ។

**២.២.២.ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

ក្នុងខែធ្នូ នេះក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៩ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ៥៨ ២៩៨ ៧៣១ ៣១៩ រៀល ស្មើនឹង ៤៣,៩៨% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ៦៩ ៧១៨ ៧៨៤ ៦៧២ រៀល ស្មើនឹង ៣៦,៦៩% នៃច្បាប់ថវិកា ។

**២.២.៣. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- ចូលរួមវគ្គបណ្តុះបណ្តាលសូចនាករសមិទ្ធកម្មថវិកាកម្មវិធី(KPIs)ដែលបង្ហាត់ ដោយ Private CEO មកពីប្រទេសអូស្ត្រាលី នៅសណ្ឋាគារសុខាភ្នំពេញ រៀបចំដោយ ក្រុមការងារអគ្គលេខាធិកាកែទម្រង់ហិរញ្ញវត្ថុសាធារណៈ
- ចូលរួមប្រជុំពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី៣ និងពិនិត្យលើការរៀបចំផែនការសកម្មភាពដំណាក់កាលទី៣ ឆ្នាំ២០២០ របាយការណ៍វឌ្ឍនភាពត្រីមាសទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងស្ថាប័ន នៅសណ្ឋាគារភ្នំពេញ ។

**២.២.៤. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ**

- រៀបចំផ្ទេរមុខងារក្នុងវិស័យអភិវឌ្ឍន៍ជនបទចំនួន ០៣ ដោយប្រគល់ទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងព្រះរាជាណាចក្រកម្ពុជាចាប់ពី ឆ្នាំ២០២០ តទៅ ។

**២.២.៥. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ**

- កែសម្រួលរបាយការណ៍សម្រាប់សន្និបាតបូកសរុបការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមដំណើរទស្សនកិច្ចនៅសាលារៀនកម្រិតមធ្យមសិក្សានៅក្នុងខេត្តមណ្ឌលគិរី ដែលរៀបចំដោយក្រុមការងារតាមដាន ត្រួតពិនិត្យការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី សូចនាករសមិទ្ធកម្មគន្លឹះ និងការគ្រប់គ្រងសមិទ្ធកម្ម
- ចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តី ព្រាងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (IDP) ក្នុងឆ្នាំ ២០១៧-២០១៨
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ

- ចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យ MIS ជំហាន ២ នៅខេត្តចំនួន ០៦ រួមមាន ខេត្តមណ្ឌលគិរី ប៉ៃលិន កំពត ពោធិ៍សាត់ បាត់ដំបង និងខេត្តក្រចេះ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ ។

**២.២.៦. ការងារអធិការកិច្ច និងសវនកម្ម**

- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យលើការងារគ្រប់គ្រងចំណូល-ចំណាយ និងការប្រើប្រាស់ថវិការបស់រដ្ឋការិយបរិច្ឆេទ២០១៨ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ។

**២.២.៧. ការងារអភិវឌ្ឍន៍ផ្លូវជនបទ និងមន្ទីរពិសោធន៍**

- គម្រោងថែទាំខួប សម្រាប់ឆ្នាំ២០១៩ មានចំនួន ២៨ គម្រោង ស្មើនឹង ៦៣ខ្សែ ប្រវែងសរុប ៣៧៥,៨៣គ.ម លទ្ធផលសម្រេចបាន ១០០%
- គម្រោងថែទាំប្រចាំ សម្រាប់ឆ្នាំ២០១៩ មានចំនួន ៤០ គម្រោង ស្មើនឹង ៣៦៩ខ្សែ ប្រវែងសរុប ២ ៨១១,២៣ គ.ម លទ្ធផលសម្រេចបាន ១០០ %
- គម្រោងជួសជុលផ្លូវបន្ទាន់ជំហ៊ាន២ មានចំនួន ២៨ គម្រោង ប្រវែងសរុប ៥៣ ៧២៦ ម និងលូមូល ០៨ កន្លែង (ក្រួសក្រហមប្រវែង ៥២ ០៦០ ម និងបេតុង ១ ៦៦៦ម ) លទ្ធផលសម្រេចបាន ១០០%
- គម្រោងផែនការស្តាបនា កែលម្អ និងជួសជុលផ្លូវជនបទប្រចាំឆ្នាំ២០១៩ មានចំនួន ៩៦ គម្រោង ប្រវែងសរុប ៤៨៩,៨៨ គ.ម សម្រេចបានលទ្ធផលដូចខាងក្រោម៖
    - គម្រោងសម្រេចបាន ១០០% មានចំនួន ៤៥ គម្រោង ស្មើនឹង ៤៣,២០% នៃចំនួនគម្រោងសរុប ៩៦ គម្រោង
    - គម្រោងសម្រេចបានលើស ៥០% មានចំនួន ៤០ គម្រោង ស្មើនឹង ៣៨,៤០% នៃចំនួនគម្រោងសរុប ៩៦ គម្រោង
    - គម្រោងសម្រេចបានក្រោម ៥០% មានចំនួន ១០ គម្រោង ស្មើនឹង ៩,៦០% នៃចំនួនគម្រោងសរុប ៩៦ គម្រោង
    - គម្រោងសម្រេចបានក្រោម ១០% មានចំនួន ០១ គម្រោង ស្មើនឹង ០,៩៦% នៃចំនួនគម្រោងសរុប ៩៦ គម្រោង
- មន្ទីរពិសោធន៍កំពុងបណ្តុះបណ្តាលការងារតេស្តនៅការដ្ឋាន (DCP Testing) ដល់ ប្រធានផ្នែក និងមន្ត្រីបច្ចេកទេស ចំនួន ១៧ នាក់ ស្រី ០២ នាក់
- មន្ទីរពិសោធន៍កំពុងបណ្តុះបណ្តាលការងារតេស្តកៅស៊ូ ភាពទន់នៃកៅស៊ូ (Softening Point of Bitumen) ជូនប្រធានផ្នែក និងមន្ត្រីបច្ចេកទេសចំនួន ១៧ នាក់ ស្រី ០២ នាក់ ដើម្បីដឹងនូវចំណាត់ថ្នាក់កៅស៊ូ និងទំនាក់ទំនងនូវលំហូរកៅស៊ូទៅនឹងសីតុណ្ហភាព ។

**២.២.៨. ការងារផ្គត់ផ្គង់ទឹកជនបទ**

- ចុះសិក្សាទីតាំងសម្រាប់សាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ នៅខេត្តបន្ទាយមានជ័យ

- បានចុះប្រមូលទិន្នន័យអណ្តូងស្នប់ដែលខូចខាតអំឡុងពេលទឹកជំនន់ ដើម្បីធ្វើការតម្លៃសម្រាប់ជួសជុល និងកែលម្អឡើងវិញ និងបណ្តុះបណ្តាលអំពីការប្រើប្រាស់ទឹក និងការថែទាំអណ្តូងស្នប់ដល់ក្រុមប្រើប្រាស់ទឹក នៅខេត្តស្ទឹងត្រែង
- បានចុះផ្ទៀតផ្ទាត់ទិន្នន័យអណ្តូងទឹក ស្រះសហគមន៍ ទំនប់ទឹក អាងត្រងទឹកភ្លៀង ប្រឡាយទឹក និងប្រព័ន្ធចែកចាយទឹកស្អាតតាមបណ្តាលស្រុក ដែលគ្រប់គ្រងដោយក្រសួងអភិវឌ្ឍន៍ជនបទ នៅខេត្តកណ្តាល ។

២.២.៩. ការងារថែទាំសុខភាព និងអនាម័យជនបទ

- បានចុះត្រួតពិនិត្យនិងជម្រុញការអនុវត្តគ្រូបង្គោលអនាម័យភូមិនៅក្នុងខេត្តគោលដៅចំនួន ១២ គឺនៅខេត្តក្រចេះ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ ត្បូងឃ្មុំ ប៉ៃលិន ព្រះសីហនុ សៀមរាប កោះកុង កែប ឧត្តមានជ័យ និងខេត្តស្វាយរៀង
- បានចុះបំផុសពីសារៈសំខាន់នៃការប្រើប្រាស់បង្គន់អនាម័យតាមសហគមន៍នៅក្នុងខេត្តប៉ៃលិន ក្រចេះ កំពង់ស្ពឺ សៀមរាប និងខេត្តឧត្តរមានជ័យ ដែលមានអ្នកចូលរួមចំនួន ១ ៥០៩ នាក់
- ក្រុមការងារនាយកដ្ឋាន (HP) បានចុះអង្កេត និងវាយតម្លៃការអនុវត្តលើកកម្ពស់អនាម័យនៅតាមសហគមន៍ចំនួន ០៥ គឺ សហគមន៍ផ្សារតូច សហគមន៍ព្រែកជីក សហគមន៍បឹងឈូក A សហគមន៍លូ និងសហគមន៍ស្ទឹងកំបុត ក្នុងរាជធានីភ្នំពេញ ដែលមានប្រជាជនចូលរួមចំនួន ៩៨ នាក់ ។ ក្នុងសកម្មភាពនោះពលរដ្ឋបានចូលរួមអនុវត្តដោយផ្ទាល់ពីការលាងសំអាតដៃជាមួយសាប៊ូ ការបរិភោគនិងទុកដាក់ទឹកដោយមានសុវត្ថិភាព ការប្រើប្រាស់បង្គន់អនាម័យ ការទុកដាក់សម្រាមឲ្យបានត្រឹមត្រូវ និងការការពារជម្ងឺតាមដង្កូវ។ ជារួមប្រជាជនភាគច្រើន មានការយល់ ដឹងពីអនាម័យ។

២.២.១០. ការងារអភិវឌ្ឍន៍សហគមន៍

- រៀបចំផែនការកម្មវិធីរបស់ការិយាល័យអភិវឌ្ឍន៍មូលដ្ឋាន ឆ្នាំ ២០២០
- ចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លីចំនួន ០៤ វគ្គ មានសិក្ខាកាមចូលរួមចំនួន ១២០ នាក់ ក្នុងនោះស្រីចំនួន ៤៩ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានធ្វើការផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទាំងនៅក្នុងមជ្ឈមណ្ឌល និងក្រៅមជ្ឈមណ្ឌលចំនួន ១២ វគ្គ មានសិក្ខាកាមចំនួន ២៤០ នាក់ ។

២.២.១១. ការងារបណ្តុះបណ្តាល

- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៥៤៤ នាក់ ស្រី ២៤២ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ១៥ នាក់ ស្រី ០១ នាក់
- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ១ ៥៧៥ នាក់ ស្រី ៤០០ នាក់

- មន្ត្រីចូលរួមសិក្ខាសាលាក្រៅប្រទេស ចំនួន ១៦ នាក់ ស្រី ០៥ នាក់
- មន្ត្រីចូលរួមទស្សនកិច្ចសិក្សាក្នុងប្រទេស ចំនួន ២៦ នាក់ ស្រី ០២ នាក់
- មន្ត្រីចូលរួមទស្សនកិច្ចសិក្សាក្រៅប្រទេស ចំនួន ០៣ នាក់
- បានរៀបចំសិក្ខាសាលាចែករំលែកចំណេះដឹង ចំនួន ០១ លើក ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៨២ រូប ស្រី ១៦ រូប
- បានរៀបចំឯកសារលិខិតចាត់បញ្ជូនមន្ត្រី ដើម្បីចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ចំនួន ០២ លើក
- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ១១ ខេត្ត រួមមាន ៖ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពត ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ បានបញ្ចប់ការងារបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈទៅតាមផែនការរបស់ខ្លួនទាំងស្រុង ។ ក្រៅពីនោះមជ្ឈមណ្ឌលបានកំពុងរៀបចំវិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនសិក្ខាកាមដែលទទួលបានជោគជ័យ រៀបចំប្រារព្ធពិធីចែកវិញ្ញាបនបត្រ ផ្តល់ជូនសិក្ខាកាម និងរៀបចំផែនការសកម្មភាពបណ្តុះបណ្តាលសម្រាប់ឆ្នាំ ២០២០ ជាបន្ត ។

### ២.២.១២. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៩ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានសរុបចំនួន ៣ ៩៩៩ ៣៣៩ ១៣៥ រៀល (បីប៊ីលានប្រាំបួនរយកៅសិបប្រាំបួនលានបីរយសាមសិបប្រាំបួនពាន់មួយរយសាមសិបប្រាំរៀល) ស្មើនឹង ១ ០១៩ ០៦០,៧៤ ដុល្លារអាមេរិក (មួយលានដប់ប្រាំបួនពាន់ហុកសិបដុល្លារនិងចិតសិបបួនសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ២៥២ នាក់ នៅភូមិគោលដៅចំនួន ២៤៤ ភូមិ ១០០ ឃុំ ៣២ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥
- បានរៀបចំពិធីតាំងពិព័ណ៌ផលិតផលខ្មែរ "ភូមិខ្ញុំ ផលិតផលខ្ញុំ" នៅខេត្តកំពង់ធំ ចំនួន ០១ លើក រយៈពេល ០២ ថ្ងៃ ដែលមានស្តង់ ចំនួន ៨០ ស្តង់ អ្នកចូលរួមទស្សនាចំនួនប្រមាណ ៣ ៤៩៦ នាក់
- បានធ្វើការប្រមូលសរុប និងសម្របសម្រួលគាំទ្រផ្នែក បច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ដែលមានស្រូវសរុបចំនួន ១០ ០០០ គ.ក្រ ស្ថិតនៅដៃសមាជិកកំពុងប្រើប្រាស់សរុបចំនួន ៨៦ នាក់ ស្រី ៦៤ នាក់ ។

### ២.២.១៣. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- បានរៀបចំសិក្ខាសាលា ស្តីពីការស្វែងរកតម្រូវការអាទិភាពសម្រាប់អភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច នៅសណ្ឋាគារ អេមព្រីសអង្គរ ខេត្តសៀមរាប ដែលមានអ្នកចូលរួម

ចំនួន ១០៥ នាក់ ក្នុងគោលបំណងដើម្បីផ្តល់ឱកាសដល់បងប្អូនជនជាតិដើមភាគតិច បានពិភាក្សា និងលើកឡើងពីតម្រូវការជាចាំបាច់ដោយផ្តោតលើជំនាញវិជ្ជាជីវៈយុវជន ជនជាតិដើមភាគតិច

- បានរៀបចំឯកសារ និងត្រៀមទទួលស្វាគមន៍គណៈប្រតិភូនៃគណៈកម្មាធិការជនជាតិដើមភាគតិចចិន ដែលនឹងមកបំពេញទស្សនកិច្ចនៅកម្ពុជា ចាប់ពីថ្ងៃទី ០៧ ដល់ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០១៩ ។

**២.២.១៤.ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**

ក្នុងខែធ្នូ ឆ្នាំ២០១៩ នេះ លេខាធិការដ្ឋានក្រុមការងារចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ទទួលបានសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន តាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត សរុបចំនួន ៣១ ករណី ក្នុងនោះក្រសួងដោះស្រាយជូនប្រជាពលរដ្ឋបានចំនួន ០៣ ករណី ។

**២.២.១៥. ការងារយេនឌ័រ**

- ចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការតាមដាន និងវាយតម្លៃការអនុវត្តអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(ស៊ីដ-ដ)
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី ៥ ឆ្នាំ ២០១៩-២០២៣
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ឧបករណ៍តាមដាន និងវាយតម្លៃពាក់ព័ន្ធសិទ្ធស្ត្រី និងយេនឌ័រ
- ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីផលប៉ះពាល់នៃកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ ។

**២.២.១៦. ការងារប្រយុទ្ធនឹងជំងឺអេដស៍**

- ប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ ២០២០ ។

**២.៣. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការទ្វេភាគី និងពហុភាគី**

**២.៣.១. គម្រោងកែលម្អផ្លូវជនបទ ដំណាក់ ២**

គិតត្រឹមដំណាច់ខែវិច្ឆិកានេះ គម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន ១០០%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១០៤,០៨ គ.ម សម្រេចបាន ៦៣,៤៧%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៦៩,៣៣%

- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១២៦,៣០ គ.ម សម្រេចបាន ៥២,១៨%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ ខ្សែ ប្រវែង ១១៣,៤០ គ.ម សម្រេចបាន ៦១,៣៥%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៥៥,៨៤%
- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១២៥,៥០ គ.ម សម្រេចបាន ១០០%
- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ ខ្សែ មានប្រវែងសរុប ១០១,២០ គ.ម សម្រេចបាន ១០០%
- ខេត្តបន្ទាយមានជ័យ :បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ១០០%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ ខ្សែ មានប្រវែងសរុប ៥០ គ.ម សម្រេចបាន ១០០%
- សាងសង់ប្រឡាយទឹកស្រោចស្រពដំណាំ និងមណ្ឌលសុខភាព នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម សម្រេចបាន ៤៧,១១ % ។

**២.៣.២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំណាក់កាលទី ៦**

គិតត្រឹមដំណាច់ខែធ្នូនេះ គម្រោងបានបញ្ចប់ការសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែងសរុប ៩,៩ គ.ម និងកំពុងដំណើរការសាងសង់ផ្លូវក្រាលក្រួសក្រហម និងផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ចំនួន ០២ ខ្សែ មានប្រវែងសរុប ៣៧,៣០ គ.ម នៅស្រុកមង្គលបូរី និងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ សម្រេចបាន ៦៤% ។

**២.៣.៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គិតត្រឹមខែធ្នូនេះ គម្រោងបាន និងកំពុងអនុវត្តចំនួន ៥៧ គម្រោង ប្រវែង ១៦៤ ០០១ ម៉ែត្រ ក្នុងខេត្តគោលដៅចំនួន ១២ ក្នុងនោះបានបញ្ចប់ការងារ បានចំនួន ០៦ គម្រោង ប្រវែងសរុប ១៨ ១៥០ ម៉ែត្រ នៅខេត្តកំពង់ឆ្នាំង ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ ។

**២.៣.៤. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២**

- សង់បង្គន់សាធារណៈ និងអាងត្រងទឹកភ្លៀងសាធារណៈបានចំនួន ១០ កន្លែង និងសាងសង់ថ្លុកហាលលាមក សម្រេចបាន ១០០% នៅខេត្តបន្ទាយមានជ័យ
- ដឹកសម្ភារបង្គន់គ្រួសារចែកជូនប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋបានធ្វើបង្គន់អនាម័យរួចរាល់បានចំនួន ១ ៩៥៨ ខ្នងផ្ទះ និងសាងសង់បង្គន់ ABC សម្រេចបាន ៥% នៅខេត្តបន្ទាយមានជ័យ ។

**២.៣.៥. គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង (Mekong Lancang Cooperation)**

- ទទួលរៀបចំសិក្ខាសាលាថ្នាក់តំបន់ និងដំណើរទស្សនកិច្ចរបស់បណ្តាប្រទេសមហាអនុ

តំបន់មេគង្គឡានឆាងកម្ពុជា ចិន ភូមា ឡាវ និងថៃ រយៈពេល ០៤ ថ្ងៃពីថ្ងៃទី ២៦ ដល់ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ នៅខេត្តសៀមរាប និងរាជធានីភ្នំពេញ ស្តីពីការចែករំលែកបទពិសោធន៍ ទាំងផ្នែកក្របខណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ និងការអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា

- ចុះតាមដានការអនុវត្តគម្រោងនៅខេត្តព្រៃវែង កណ្តាល ក្រចេះ និងខេត្តស្ទឹងត្រែង
- រៀបចំសិក្ខាសាលា ស្តីពីការចូលរួមរបស់សហគមន៍សម្រាប់ទឹកស្អាត និងអនាម័យ និងការការពារបរិស្ថាន ចំនួន ០៤ លើក
- រៀបចំកម្មវិធីផ្សព្វផ្សាយ ស្តីពីការមានទម្លាប់ល្អក្នុងការទុកដាក់សម្រាមនៅក្នុងសហគមន៍ ចំនួន ០៣ លើក
- សាងសង់បង្គន់អនាម័យ ចំនួន ១៤ បង្គន់
- សាងសង់ចង្ក្រានបច្ចេកទេស ចំនួន ១០ ចង្ក្រាន
- ចុះបេសកកម្មសិក្សាលទ្ធភាពទីតាំងសាងសង់ផ្សារជនបទ នៅខេត្តកំពង់ឆ្នាំង
- បានប្រគល់ជូននូវឃ្លាំងសម្រាប់ដាក់តុ-កៅអី ដល់ឃុំជើងគ្រាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
- ធ្វើកិច្ចលទ្ធកម្មរួចរាល់ដើម្បីជ្រើសរើសស្ថាបត្យករគូរប្លង់មេ សម្រាប់ការសាងសង់ផ្សារជនបទ
- ផ្សព្វផ្សាយលើកាសែត ស្តីពីការអញ្ជើញការចូលរួមដាក់ដេញថ្លៃកម្រិតថ្នាក់ជាតិលើកិច្ចលទ្ធកម្មសាងសង់ផ្សារជនបទចំនួន ០៤ ទីតាំង ។

## ៣. ទិសដៅបន្ត

### ៣.១. បញ្ហាប្រឈម

- ខេត្តមួយចំនួន (ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកោះកុង) មានតែផ្លូវប្រភេទទី៤ នាំឲ្យមានការលំបាកក្នុងការកសាងផែនការថែទាំប្រចាំឆ្នាំ
- ឧបករណ៍ពិសោធន៍មួយចំនួនពុំទាន់បានបណ្តុះបណ្តាលដល់វិស្វករ និងមន្ត្រីជំនាញ បម្រើការងារនៅមន្ទីរពិសោធន៍
- ទាមទារពេលវេលាវែង ដើម្បីជំរុញការផ្លាស់ប្តូរទម្លាប់របស់ប្រជាជន ក្នុងការប្រតិបត្តិអនាម័យល្អ
- តំបន់ខ្លះខ្វះទឹកដែលអាចប៉ះពាល់ដល់ស្ថានភាពអនាម័យ
- ទម្លាប់សង្គមក្នុងការបន្ទោបង់ពាសវាលពាសកាល មិនទម្លាប់ផឹកទឹកស្អាត និងការលាងដៃឲ្យបានត្រឹមត្រូវ ខ្វះការយល់ដឹង ដែលនាំឲ្យកម្រិតវិនិយោគពីគ្រួសារទាប
- ទីផ្សារអនាម័យនៅមានកម្រិត (បច្ចេកវិទ្យា ផលិតផល ការផ្គត់ផ្គង់បរិក្ខារអនាម័យ)
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- ស្ថាប័ន ឬអង្គការមួយចំនួន មិនបានប្រើប្រាស់ គ.អ.ភ ហើយបានបង្កើតជនបង្គោលផ្សេងៗពី គ.អ.ភ
- ចំណេះដឹង និងការចូលរួមរបស់ជនជាតិដើមភាគតិចនៅមានកម្រិត ។

៣.២. ទិសដៅតាមអង្គភាព

- បន្តចុះធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ
- ធ្វើបច្ចុប្បន្នភាពផ្លូវប្រភេទ ទី៤ ទី៣ និងទី២ ដើម្បីមានភាពងាយស្រួលក្នុងការ កសាងផែនការ
- បន្តរៀបចំផែនទី សម្រាប់ការងារថែទាំខួប និងប្រចាំ ឆ្នាំ ២០២១ និង ឆ្នាំ ២០២២
- ត្រៀមកសាងផែនការសកម្មភាពការងារ ឆ្នាំ ២០២០ សម្រាប់ការធ្វើបច្ចុប្បន្នភាពការស្រង់ទិន្នន័យផ្លូវថ្មី និងការបញ្ចូលខ្សែផ្លូវក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំ ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពឯកសារគតិយុត្តសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ
- ផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បន្តសហការសាកល្បងការផ្ទេរមុខងារអនាម័យទៅរដ្ឋបាលថ្នាក់ស្រុកទាំង ១៥ ក្នុងខេត្តគោលដៅទាំងបី គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- ត្រៀមរៀបចំពិនិត្យសារឡើងវិញនូវផែនការសកម្មភាពជាតិ ជំហានទី ១ (២០១៤-២០១៨) និងរៀបចំធ្វើផែនការសកម្មភាពជាតិជំហានទី ២ ស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យជនបទ (២០១៩-២០២៣ )
- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រី
- បន្តជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឲ្យបង្កើតសហគ្រាសខ្នាតគ្រួសារ និងខ្នាតតូច
- ពង្រឹងការផ្តល់សេវាជូនប្រជាពលរដ្ឋដូចជាការងារឥណទានសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ ការបណ្តុះបណ្តាលបំនិនជីវិត ការរកទីផ្សារសម្រាប់ផលិតផលជនបទជាដើម
- ពន្លឿនការចុះកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- បន្តសិក្សាភូមិគោលដៅដើម្បីរៀបចំចុះវាយតម្លៃអត្តសញ្ញាណជនជាតិដើមភាគតិចបន្ត
- បន្តស្វែងយល់អំពីតម្រូវការរបស់យុវជនជនជាតិដើមភាគតិច
- បន្តចូលរួមកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈជំហានទី៣
- រៀបចំផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល និងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ ។

**៤.សេចក្តីសន្និដ្ឋាន**

ឈានចូលដល់ចុងឆ្នាំ២០១៩ នេះ ក្រសួងអភិវឌ្ឍន៍ជនបទបានធ្វើសកម្មភាពជាច្រើនដើម្បីឈានទៅសម្រេចគោលដៅរបស់ខ្លួន ក្នុងការលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាជនជនបទដើម្បីឈានទៅបង្កើតលក្ខខណ្ឌរស់នៅកាន់តែប្រសើរឡើងទាំងសុខភាព ជីវភាព និងសុវត្ថិភាព ដើម្បីចូលរួមថែរក្សាសន្តិភាព ដែលប្រទេសជាតិយើងកំពុងមានស្រាប់ ឲ្យបានគង់វង្សក្រោមការដឹកនាំពោរពេញដោយមនសិការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៕

**រដ្ឋមន្ត្រី**

បណ្ឌិត អ៊ុក រ៉ាប៊ុន